

# PreK 4 ME ការផ្សារភ្ជាប់គ្រួសារ

## មេរៀនទី 4 ៖ ពិភពពណ៌

### *ទិដ្ឋភាពទូទៅនៃមេរៀនទី 4 ៖ ពិភពពណ៌*

នៅក្នុងថ្នាក់រៀន គឺយើងនាំគ្នាចាប់ផ្តើមស្វែងយល់ពីពណ៌ក្នុងពិភពលោកយើង ។ យើងនឹងរៀនអំពីមុខងារនៃពណ៌នៅក្នុងលោករបស់យើង និងក្នុងធម្មជាតិ ។ កុមារនឹងអនុវត្តសកម្មភាពការលាយពណ៌ រួមទាំងការលាបពណ៌ព្រឿងៗ និងការលាបពណ៌ជាស្រមោល ពេលដែលយើងរៀនពាក្យថ្មីបន្ថែមទៀត ។ នៅក្នុងកន្លែងសម្រាប់បង្ហាញការពិត កុមារនឹងអនុវត្តសកម្មភាពការបោកគក់ និងការសម្ងួត ដែលពួកគេត្រូវធ្វើដោយខ្លួនឯង ។ យើងនឹងបន្តពង្រឹងជំនាញគណិតវិទ្យារបស់យើង ដោយលេងល្បែងគណិតវិទ្យាជុំវិញការរាប់ទៅមុខ និងការរាប់ថយក្រោយ ការដាក់ចំនួនឲ្យត្រូវគ្នា និងការតម្រៀបតាមលេខរៀង... និងការផ្លាស់វេនគ្នា ក៏ដូចជាចែករំលែកគ្នាក្នុងពេលតែមួយ ។

### សៀវភៅសំខាន់សម្រាប់មេរៀនទី 4




*Max's Dragon Shirt*

រៀបរៀងដោយ Rosemary Wells




*Dog's Colorful Day*

ដោយ ៖ Emma Dodd




*The Color of Us*

ដោយ ៖ Karen Katz




*The Lion and the Little Red Bird*

ដោយ ៖ Elisa Kleven

រូបភាពទាញយកពី amazon.com

### សៀវភៅផ្សេងទៀតសម្រាប់អានក្នុងខែនេះ រួមបញ្ចូល...

**Is It red? Is It Yelllow? Is It Blue?** ដោយ Tana Hoban

**Perfect Square** *ដោយ Michael Hall*

**Sugaring** *ដោយ Jesse Haas*

**Backyard Birds** ដោយ Robert Bateman

## ចម្រៀង ការលេងពាក្យ និងតួអក្សរ

ក្មេងក្នុងថ្នាក់រៀន ចូលចិត្តសកម្មភាពទាក់ទងនឹងពាក្យច្ចូនគ្នានេះ! សូមអានជាមួយកូនអ្នក ហើយឲ្យគាត់បង្រៀនអ្នកពីកាយវិកា នៅពេលគាត់ថាពាក្យទាំងនោះ

*ក្រោកឈរ*

ក្រោកឈរ បែក្រោយ ។
ទះដៃប្អូនដង កុំអង្គុយចុះ ។
ទះដៃម្តងទៀត សូមគោរព ។
ទន្ទ្រាំជើង ឈប់ទន្ទ្រាំ ។
បោយដៃអ្នក បន្ទន់ជង្គង់ទាំងពីរ ។
អង្គុយចុះវិញ ហើយងាកមកមើលខ្ញុំ ។



រូបភាពយកចេញពី Pixabay

សូមអានទំព័រម្ខាងទៀតអំពីសកម្មភាពនៅផ្ទះ

# ចូរបង្កើតការរៀនសូត្រនៅផ្ទះ ដោយប្រើសកម្មភាពបន្ថែមទាំងអស់នេះ!

## វិទ្យាសាស្ត្រ វិធីសាស្ត្រការរៀនសូត្រ សិល្បៈច្នៃប្រឌិត ការបញ្ជាភ្នែក និងម្រាមដៃ និងការប្រើសាច់ដុំដៃជើង

### ដើរមើលពណ៌

ដោយប្រើទំព័រដែលដាក់ភ្ជាប់មកជាមួយ នាំកូនអ្នកដើរមើលពណ៌ ។ អ្នកអាចនាំគាត់ដើរមើលខាងក្រៅផ្ទះ ក្នុងផ្ទះ បណ្ណាល័យ ហាងលក់ឥវ៉ាន់—កន្លែងណាក៏បានដែលអ្នកនាំកូនដើរ!

ឲ្យកូនអ្នកគូរជាគំនូរ ឬជារូបភាព នូវប្រអប់ដែលមានរបស់ដែលគាត់ឃើញ ដែលមានពណ៌ដូចគ្នានឹងខ្មៅដៃពណ៌នៅក្នុងប្រអប់នីមួយៗ ។

ជជែកជាមួយគាត់អំពីពណ៌ របស់ដែលបានឃើញ និងរបស់ផ្សេងទៀត ដែលមានពណ៌ដូចគ្នានឹងខ្មៅដៃពណ៌ក្នុងប្រអប់!

## វិទ្យាសាស្ត្រ សុខភាព ការប្រើភ្នែក និងម្រាមដៃ វិធីសាស្ត្ររៀនសូត្រ

### ការញ៉ាំឥណ្ឌនូ

នេះជាវិធីនាំមកនូវភាពរីករាយ ក្នុងការយកពណ៌បញ្ចូលក្នុងម៉ោងញ៉ាំអាហារសម្រន់! ប្រើរបស់សម្រាប់ញ៉ាំជាអាហារសម្រន់ក្នុងផ្ទះរបស់អ្នក ឬរៀបចំផែនការចេញទៅកាន់ហាងលក់គ្រឿងទេស ដើម្បីរករបស់ថ្មី។ សូមជ្រើសរើសអាហារ 3 ឬ 4 មុខ ដែលមានពណ៌ខុសគ្នា ហើយឲ្យកូនអ្នកជួយរៀបចំចម្អិនម្ហូបនេះជាមួយអ្នក ។ ម្រេចពណ៌ ផ្លែប៉ោម នំស្រួយ ឈីស—អាហារជាច្រើន មានពណ៌ខុសៗគ្នា!

## គណិតវិទ្យា អារម្មណ៍សង្គម វិធីរៀនសូត្រ ការសិក្សាភាសា និងការសិក្សាសង្គម

### ថ្ងៃបោកគក់

នេះជាថ្ងៃបោកគក់! ឲ្យកូនអ្នកជួយរៀបចំខោអាវទៅតាមពណ៌ ។ អ្នកអាចឲ្យគាត់រៀបចំតាមរបៀបផ្សេងៗគ្នា មានដូចជា ៖

◊ ខោអាវពណ៌ថ្លា និងពណ៌ស្រគាំ

◊ ខ្មៅ ស និងក្រហម

◊ រៀបស្រោមជើងទៅតាមពណ៌របស់វា

និយាយជាមួយកូនអំពីពណ៌ ស្រមោលពណ៌ខុសៗគ្នាដែលមើលឃើញ ស្វាបក្រណាត់ ។



រូបភាពយកចេញពី Pixabay

## បណ្ដាំដល់ឪពុកម្ដាយ និងគ្រួសារ ៖ ភាពជាប់លាប់ជាគន្លឹះ

កុមាររៀនចេះដឹងតាមភាពជាប់លាប់ ៖ នៅក្នុងកាលវិភាគប្រចាំថ្ងៃរបស់គាត់ នៅក្នុងការគោរពវិន័យរបស់គាត់ ព្រមទាំងអាចក្នុងការជ្រើសរើសអាហាររបស់គាត់!

ការដែលអ្នកអាចធ្វើអ្វីមួយឲ្យមានភាពជាប្រចាំ និងទៀងទាត់ គឺវាកាន់តែធ្វើឲ្យកូនអ្នកមានភាពរីករាយទៅតាមនោះដែរ ។ នៅពេលដែលកូនអ្នកដឹងថា អ្វីនឹងកើតឡើង វាធ្វើឲ្យអារម្មណ៍របស់ពួកគេស្ងប់ស្ងាត់ ។ បើសិនជាមានការផ្លាស់ប្ដូរចំពោះសកម្មភាពប្រចាំថ្ងៃរបស់អ្នក ត្រូវប្រាប់កូនអ្នកឲ្យបានដឹងជាមុន ដើម្បីឲ្យពួកគេបានត្រៀមខ្លួនរួចរាល់ ។

ស្ថានភាពនេះ អាចប្រើបានជាពិសេស ចំពោះអាកប្បកិរិយា និងរបៀបវិន័យ ។ កុមារគួរដឹងជាក់លាក់ថាអ្វីអាចធ្វើបាន និងអ្វីមិនអាចធ្វើបាន ។ ពួកគេក៏គួរដឹងផងដែរថា តើនឹងមានអ្វីកើតឡើង បើសិនជាពួកគាត់មិនធ្វើតាមបទបញ្ជា ។

ព័ត៌មាននេះ ដកស្រង់ចេញពី http://www.the-preschool-professor.com/10-parenting-tips.html

# ការចេញដើរមើលពណ៌

នាំកូនដើរមើលខាងក្រៅ ព្រមទាំងសង្កេតមើលរបស់ជុំវិញខ្លួនអ្នក ។ រកមើលរបស់ក្នុងពេលកំពុងដើរ ដែលតំណាងឲ្យពណ៌នីមួយៗ ។ គូររូបភាពរបស់នីមួយៗ ដែលត្រូវទៅតាមពណ៌ក្នុងប្រអប់ ។











